# ពាក្យគួរចងចាំ

កុំឃើញកាលវែង កុំឃើញកាលខ្លី គឺថាកុំប្រញាប់បែកចាកពួកមិត្តសំឡាញ់ឡើយ

**នាញ្ញត្រ សុចរិតំ រាជ នាញ្ញត្រ រាជ សុភាសិតំ**
**តាយតេ មរណកាលេ ឯវមេវិតរំ ធនំ ។**

បពិត្រព្រះរាជា អ្វីដទៃក្រៅពីសុចរិត និងវាចាដែលជាសុភាសិតគឺមិន អាចការពារព្រះជន្មរបស់ព្រះអង្គ កុំឲ្យដល់ នូវមរណៈ ក្នុងពេល នេះ បានឡើយ ទ្រព្យក្រៅពីនេះ ក៏យ៉ាងនោះដែរ ។

**អក្កោច្ឆិ មំ អវធិ មំ អជិនិ មំ អហាសិ មេ**
**យេ ច តំ ឧបនយ្ហន្តិ វេរំ តេសំ ន សម្មតិ ។**

បុគ្គលទាំងឡាយណា ចងនូវពៀរនោះ ដោយគិតថា អ្នកឯណោះ បាន ជេរអញ បានវាយអញ បានផ្ចាញ់អញ បាន លួចយកទ្រព្យ របស់ អញ ដូច្នេះ ពៀររបស់បុគ្គលទាំងឡាយនោះ រមែងមិនរម្ងាប់ឡើយ ។

**អក្កោច្ឆិ មំ អវធិ មំ អជិនិ មំ អហាសិ មេ**

**យេ ច តំ នូបនយ្ហន្តិ វេរំ តេសូបសម្មតិ ។**

បុគ្គលទាំងឡាយណា មិនចងនូវពៀរនោះថា អ្នកឯណោះ បានជេរអញ បានវាយអញ បានផ្ចាញ់អញ បានលួច យកទ្រព្យរបស់អញ ដូច្នេះ ពៀររបស់បុគ្គលទាំងឡាយនោះ ទើបរម្ងាប់បាន ។

**ន ហិ វេរេន វេរានិ សម្មន្តីធ កុទាចនំ**

**អវេរេន ច សម្មន្តិ ឯស ធម្មោ សនន្តនោ ។**

ក្នុងកាលណាក៏ដោយ ធម្មតាពៀរទាំងឡាយ ក្នុងលោកនេះ មិនដែល ស្ងប់រម្ងាប់ ដោយការចងពៀរឡើយ ពៀរទាំងឡាយ តែងស្ងប់រម្ងាប់ ដោយការមិនចងពៀរ នេះជាធម៌ចាស់មានយូរយា ណាស់មកហើយ ។

**សូមអស់លោកអ្នកអនុមោទនា** !